ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា កន្លងមកក្រសួងបានខិតខំយ៉ាងសកម្មក្នុងការចរចាបើកទីផ្សារផ្លែមៀនប៉ៃលិនដែលបានចាប់ផ្តើមតាំងពីឆ្នាំ២០១៩ ដោយបានធ្វើការពិភាក្សាជាមួយអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន និងមានការចូលរួមសហការយ៉ាងជិតស្និទ្ធពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត អាជ្ញាធរដែនដី និងប្រជាកសិករដែលជាម្ចាស់ចម្ការចំនួន២លើក ដែលលើកទី១ ប្រព្រឹត្តទៅកាលពីខែមករា ឆ្នាំ២០២២ ដោយអគ្គរដ្ឋបាលគយចិន បានធ្វើការវាយតម្លៃហានិភ័យដោយពិនិត្យជាប្រព័ន្ធដែលជាផ្នែកមួយនៃការចរចាគ្នាលើលក្ខខណ្ឌតម្រូវភូតគាមអនាម័យ ហើយលើកទី២ ប្រព្រឹត្តទៅកាលពីថ្ងៃទី១២-១៥ ខែកក្កដា ឆ្នាំ២០២២ ដោយអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន បានដំណើរការត្រួតពិនិត្យតាមប្រព័ន្ធវីដេអូអំពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់នាំចេញផ្លែមៀនស្រស់កម្ពុជាទៅកាន់ប្រទេសចិនចំពោះតែកសិដ្ឋាន និងរោងចក្រវេចខ្ចប់ដែលយើងបានស្នើសុំចុះបញ្ជីតែប៉ុណ្ណោះ ហើយកំពុងរង់ចាំការអនុម័តពីអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិនសម្រាប់ការនាំចេញ។

ទន្ទឹមគ្នានេះដែរ ដើម្បីផ្សព្វផ្សាយឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករនៅមូលដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានធ្វើការបណ្តុះបណ្តាលស្តីពីការអនុវត្តកសិកម្មល្អ (GAP) ដល់កសិករបានជាងមួយម៉ឺននាក់ ក្នុងនោះក៏មានកសិករដាំដុះដំណាំមៀនផងដែរ ដោយផ្អែកតាមសំណើរបស់ម្ចាស់ចម្ការ គិតត្រឹមខែមិថុនា ឆ្នាំ២០២២នេះ អគ្គនាយកដ្ឋានកសិកម្មក៏បានដំណើរការវាយតម្លៃការចុះបញ្ជីចម្ការមៀនប៉ៃលិនជាចម្ការអនុវត្តកសិកម្មល្អបានចំនួន៧២ចម្ការរួចមកហើយ។ ឆ្លៀតក្នុងឱកាសនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្នើសុំម្ចាស់ចម្ការមៀនប៉ៃលិនដែលមិនទាន់ទទួលបានការបណ្តុះបណ្តាលស្តីពីការអនុវត្តកសិកម្មល្អ មេត្តារួតរះចុះឈ្មោះចូលរៀនតាមការអំពាវនាវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដាក់ពាក្យចុះបញ្ជីចម្ការនិងរោងចក្រវេចខ្ចប់ផ្លែមៀនសម្រាប់នាំចេញទៅកាន់ប្រទេសចិនឱ្យបានផុសផុលបន្ថែមទៀត។ ដោយឡែក ចំពោះម្ចាស់ចម្ការនិងរោងចក្រវេចខ្ចប់ផ្លែមៀនដែលបានចុះបញ្ជីសម្រាប់នាំចេញរួចហើយ សូមព្យាយាមអនុវត្តឱ្យបានល្អប្រសើរតាមស្តង់ការនៃការអនុវត្តកសិកម្មល្អ ការគ្រប់គ្រងសមាសភាពចង្រៃប្រកបដោយភាតរបរិស្ថាន ការប្រើប្រាស់ថ្នាំកសិកម្មប្រកបដោយសុវត្ថិភាព និងគោលការណ៍បច្ចេកទេសក៏ដូចជាលក្ខខណ្ឌតម្រូវភូតគាមអនាម័យរបស់ប្រទេសនាំចូល។

សម្រាប់ការនាំចេញគ្រាប់ពោតទៅកាន់ប្រទេសថៃ យោងតាមលិខិតលេខ AC 0914/1629 ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់នាយកដ្ឋានកសិកម្មថៃ ស្តីពីការនាំចូលគ្រាប់ពោតពីកម្ពុជាទៅប្រទេសថៃ ភាគីថៃបានដាក់លក្ខខណ្ឌតម្រូវថ្មី ដោយតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតនាំចូលជាមុន និងគ្រាប់ពោតត្រូវធ្វើធូបនកម្ម (Fumigation) នៅមុនពេលនាំចេញដោយប្រើថ្នាំ Methyl bromide ដែលថ្នាំនេះ ជាប្រភេទថ្នាំមានតម្លៃថ្លៃ និងស្ថិតក្នុងបញ្ជីថ្នាំកសិកម្មដែលអាចអនុញ្ញាតឱ្យប្រើប្រាស់ដោយមានលក្ខខណ្ឌជាក់លាក់ណាមួយតែប៉ុណ្ណោះ ក្រោមការត្រួតពិនិត្យផ្ទាល់ពីសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពីព្រោះជាប្រភេទថ្នាំធ្វើឱ្យប៉ះពាល់ដល់ស្រទាប់អូហ្សូនផងដែរ។ បច្ចុប្បន្ន នៅប្រទេស

កម្ពុជា ក៏មានក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងមានលទ្ធភាពផ្តល់សេវាធូបនកម្ម (Fumigation) លើថ្នាំប្រភេទនេះផងដែរ ប៉ុន្តែដោយសារថ្នាំនេះមានតម្លៃថ្លៃ ធ្វើឱ្យតម្លៃគ្រាប់ពោតកើនឡើងមួយកម្រិតទៀតធ្វើឲ្យប៉ះពាល់ដល់ការនាំចេញពោត។ ក្នុងបរិការណ៍នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានធ្វើការចរចាជាមួយភាគីថៃជាច្រើនលើកច្រើនសា ដោយស្នើសុំភាគីថៃដកលក្ខខណ្ឌប្រើប្រាស់ថ្នាំ Methyl bromide ចេញនិងជំនួសវិញដោយថ្នាំ Phosphine។ ប៉ុន្តែភាគីថៃមិនយល់ព្រមតាមការស្នើសុំរបស់ភាគីកម្ពុជាឡើយ ដោយបញ្ជាក់ថា លក្ខខណ្ឌនេះត្រូវបានដាក់ចំពោះគ្រប់ប្រទេសនាំគ្រាប់ពោតចូលប្រទេសថៃ ពោលគឺមិនចំពោះតែប្រទេសកម្ពុជាទេ។ ទោះជាយ៉ាងនេះក្តី ក៏នៅមានការនាំចេញគ្រាប់ពោតជាផ្លូវការទៅកាន់ប្រទេសថៃដោយគោរពតាមលក្ខខណ្ឌតម្រូវថ្មីរបស់ប្រទេសថៃនេះបានចំនួន ៣៧ ៥០០តោន ផងដែរ គិតត្រឹមថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ នេះ។

ចំពោះដំណាំពោតដែលបានធ្វើការដាំដុះសម្រាប់នាំចេញធ្វើជាចំណីសត្វ គឺមិនតម្រូវឱ្យមានការចុះបញ្ជីជាចម្ការអនុវត្តកសិកម្មល្អ (GAP) ឡើយ។ ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានចុះបញ្ជីឈ្មោះក្រុមហ៊ុននាំចេញគ្រាប់ពោតទៅកាន់ប្រទេសចិន និងបានធ្វើការត្រួតពិនិត្យស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញគ្រាប់ពោតកម្ពុជាទៅកាន់ប្រទេសចិនតាមរយៈអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិនរួចរាល់ផងដែរ ដោយនៅរង់ចាំតែការអនុម័តពីអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិនសម្រាប់ការនាំចេញតែប៉ុណ្ណោះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្សព្វផ្សាយពីការងារខាងលើនេះជាបន្តបន្ទាប់ទៅតាមប្រព័ន្ធផ្សព្វផ្សាយសង្គមនានា ជាពិសេសក្នុងសន្និសីទសារព័ត៌មានអំពីលទ្ធផលការងារដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រេចបាន ហើយក្រសួងនឹងបន្តកិច្ចសហប្រតិបត្តិការជាមួយអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ក្នុងបរិបទនៃសាកលភាវូបនីយកម្ម។ ក្នុងករណីដែលសាធារណជនចង់ស្វែងយល់បន្ថែមអំពីបញ្ហាខាងលើនេះឲ្យបានទូលំទូលាយ សូមមេត្តាទំនាក់ទំនងទៅអង្គភាពជំនាញជាសេនាធិការ ក្នុងនោះមានអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមសាធារណជននិងប្រជាកសិករមេត្តាជ្រាបជាព័ត៌មាន និងចូលរួមចំណែកក្នុងស្មារតីជួយលើកកម្ពស់ផលិតភាព និងមោទកភាពផលិតផលកសិកម្មជាតិយើងជាក់ជាមិនខាន។

ថ្ងៃព្រហស្បតិ៍ ៨ រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**